អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០១២សារ-១៧ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៧

# សេចក្តីសម្រេច

# ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីពិសេសសម្រាប់ប៉ះប៉ូវបន្ថយអត្រាថ្លៃលក់អគ្គិសនីដុំ ឲ្យក្រុមហ៊ុន កោះកុង យូធីលីធី ត្រូវលក់ឲ្យអ្នកកាន់អាជ្ញាបណ្ណចែកចាយ តាមអត្រា ដូចការអនុវត្ត នៅតំបន់ដទៃ

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- បានឃើញប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ៤២១.រថ.អរថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០
- សេចក្តីសម្រេចរបស់អគ្គិសនីកម្ពុជា លេខ០៤៩.សរ.១៦.អអក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦
- យោងអាជ្ញាបណ្ណ លេខ០០១.អ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងលិខិតស្នើសុំរបស់អគ្គិសនីកម្ពុជា លេខ ៥៦៥១.លស.អក.ផយក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៣១៤ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

## សម្រេច

### ប្រការ១

ដើម្បីផ្តល់លទ្ធភាពឲ្យក្រុមហ៊ុន កោះកុង យូធីលីធី ដែលជាអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង អាចលក់អគ្គិសនីដុំលើតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ចេញពីខ្សែបណ្តាញបញ្ជូនរងរបស់ខ្លួន ឲ្យអ្នកកាន់អាជ្ញាបណ្ណចែកចាយ តាមបណ្តោយផ្លូវជាតិលេខ ៦ នៅក្នុងស្រុកប្រាសាទបាគង ស្រុកសូទ្រនិគម និងស្រុកជីក្រែង ខេត្តសៀមរាប តាមអត្រា 0.145 $US/kWh ដូចគ្នានឹងតំបន់ផ្គត់ផ្គង់ដែលយកប្រភពអគ្គិសនីបណ្តាញជាតិដទៃទៀតនោះ កំណត់បញ្ជីថ្លៃលក់អគ្គិសនីពិសេស ដែលអគ្គិសនីកម្ពុជា ត្រូវលក់ឲ្យក្រុមហ៊ុន កោះកុង យូធីលីធី ដែលត្រូវទិញប្រភពអគ្គិសនីពីទ្វារចរន្តតង់ស្យុងមធ្យម MV របស់បណ្តាញជាតិ តាមលក្ខខណ្ឌ និងអត្រា ដូចខាងក្រោម ៖



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| លក្ខខណ្ឌ | អត្រាថ្លៃលក់ |
|---|---|
| បរិមាណថាមពលទិញមិនលើសពី 2,600,000 kWh ក្នុង ១ ខែ | 0.121 $US / kWh |
| បរិមាណថាមពលទិញចាប់ពី 2,600,001 ដល់ 3,000,000 kWh ក្នុង ១ ខែ | 0.124 $US / kWh |
| បរិមាណថាមពលទិញចាប់ពី 3,000,001 kWh ឡើងទៅ ក្នុង ១ ខែ | 0.126 $US / kWh |

**ប្រការ២**

អត្រាថ្លៃថ្មីដែលបានកំណត់ក្នុងប្រការ ១ ខាងលើនេះ ត្រូវអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញ ចាប់ពីដើមខែមីនា ឆ្នាំ២០១៧ តទៅ ដែលត្រូវនឹងការចេញវិក្កយបត្រនៅចុងខែមីនា ឬដើមខែមេសា ។ ក្នុងករណីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងអគ្គិសនីកម្ពុជា និងអ្នកទិញបានចែងនូវអត្រាថ្លៃខុសពីការកំណត់ក្នុងប្រការ ១ ខាងលើ អគ្គិសនីកម្ពុជា និងក្រុមហ៊ុន កោះកុង យូធីលីធី ត្រូវធ្វើការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីនៅក្នុងកិច្ចព្រមព្រៀងទិញលក់នោះឡើងវិញជាបន្ទាន់ ដើម្បីអនុវត្តអត្រាថ្លៃលក់អគ្គិសនីឲ្យស្របតាមការកំណត់ នៅក្នុងសេចក្តីសម្រេចនេះ ។ ការកែសម្រួលកិច្ចព្រមព្រៀងទិញលក់ឡើងវិញនេះ ប្រសិនបើមាន ត្រូវតែធ្វើយ៉ាងណាឲ្យអត្រាថ្លៃថ្មីអាចអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញ ចាប់ពីដើមខែមីនា ឆ្នាំ២០១៧ តទៅ ។ បច្ចុប្បន្ន ដោយក្រុមហ៊ុនកំពុងទិញអគ្គិសនីពីអគ្គិសនីកម្ពុជា តាមចុងខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដូច្នេះ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចសាងសង់ខ្សែបណ្តាញភ្ជាប់បណ្តាញរបស់ខ្លួន ទៅនឹងទ្វារចេញនៃតង់ស្យុងមធ្យមនៃអនុស្ថានីយខាងកើតក្រុងសៀមរាប ក្នុងរយៈពេល ៤ ខែយ៉ាងយូរ គិតថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧ ។

**ប្រការ៣**

លើងលែងតែការកំណត់ពេលវេលាដែលចែងក្នុងប្រការ ២ ខាងលើ ខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ដើម្បីអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ បញ្ជីថ្លៃលក់នេះ អាចធ្វើការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ បញ្ជីថ្លៃលក់អគ្គិសនីចេញមុនទាំងឡាយ ដែលផ្ទុយពីខ្លឹមសារនៃលិខិតអនុញ្ញាតនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤**

ក្នុងការទិញអគ្គិសនីពីអគ្គិសនីកម្ពុជា តាមប្រការខាងលើនេះ ក្រុមហ៊ុន កោះកុង យូធីលីធី ត្រូវរក្សាមេគុណអានុភាព (cosφ) នៃការទទួលអគ្គិសនីរបស់ខ្លួនឲ្យឋិតនៅក្នុងកម្រិតគុណភាព cosφ $\geq$ 0.9 ឬ tgφ $\leq$ 0.484 មានន័យថា ក្រុមហ៊ុន កោះកុង យូធីលីធី មានសិទ្ធប្រើប្រាស់ថាមពលរ៉េអាក់ទីវ ចេញពីប្រព័ន្ធផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជា មិនលើសពីចំនួនកំណត់មួយដែលកំណត់ដោយ cos > 0.9 ឬ tg < 0.484 ។ ក្នុងករណីដែលក្រុមហ៊ុន កោះកុង យូធីលីធី ខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវ ពីប្រព័ន្ធរបស់អគ្គិសនីកម្ពុជា លើសពីចំនួនកំណត់ ក្រុមហ៊ុន កោះកុង យូធីលីធី ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើនឹង 0.025 $US ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។


**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៨៧៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**ប្រការ៥**

អគ្គិសនីកម្ពុជា និងក្រុមហ៊ុន កោះកុង យូធីលីធី កាន់អាជ្ញាបណ្ណបញ្ជូនរង ត្រូវមានការកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព។

**ប្រការ៦**

អគ្គិសនីកម្ពុជា មានភារកិច្ចផ្សព្វផ្សាយ អំពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ដល់ក្រុមហ៊ុន កោះកុង យូធីលីធី កាន់អាជ្ញាបណ្ណបញ្ជូនរង ដែលមានការពាក់ព័ន្ធ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូន</u>
-ក្រសួងរ៉ែ និងថាមពល
"ដើម្បីជូនជ្រាប"
-អគ្គិសនីកម្ពុជា
-ក្រុមហ៊ុន កោះកុង យូធីលីធី
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ